ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តបន្ទាយមានជ័យ

រដ្ឋបាលក្រុងសិរីសោភ័ណ

លេខ:០១០.....ដក/កសរក

# ដីកា

## ស្តីពី

## ការកំណត់ និងដាក់ឱ្យអនុវត្តតម្លៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ

## ក្រុមប្រឹក្សាក្រុងសិរីសោភ័ណ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ: ២៨៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់រៀបចំកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ: ៨៧៣ អនក្រ.តត ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០២៤ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាក្រុងសិរីសោភ័ណ នៃខេត្តបន្ទាយមានជ័យ
- ប្រកាសអន្តរក្រសួងលេខ:១៩៥ ប្រក.បស្ក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការកំណត់តម្លៃអតិបរិមានៃសេវាគ្រប់គ្រងសំណល់រឹងទីប្រជុំជន

/.

អាសយដ្ឋាន: ផ្លូវជាតិលេខ៥៦A ភូមិខ្លាកូនបាស់ សង្កាត់កំពង់ស្វាយក្រុងសិរីសោភ័ណ
Page: www.facebook.com/រដ្ឋបាលក្រុងសិរីសោភ័ណ - serieysophon municipality
Telegram: 092 293 939/ 017 538 802/012 311 811

- យោងស្មារតីអង្គប្រជុំសាមញ្ញលើកទី៥ របស់ក្រុមប្រឹក្សាក្រុងសិរីសោភ័ណអាណត្តិទី៤ នាថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤ ស្តីពីការពិនិត្យ និងអនុម័តតារាងឧបសម្ព័ន្ធកំណត់កម្រៃសេវាគ្រប់គ្រងសំរាម សំណល់ទីប្រជុំជនក្រុងសិរីសោភ័ណ
- យោងស្មារតីអង្គប្រជុំសាមញ្ញលើកទី១៣របស់ក្រុមប្រឹក្សាក្រុងសិរីសោភ័ណអាណត្តិទី៤ នាថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៥ ស្តីពីការកំណត់ និងដាក់ឱ្យអនុវត្តកម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជនក្រុងសិរីសោភ័ណ
- យោងតាមការចាំបាច់របស់រដ្ឋបាលក្រុងសិរីសោភ័ណ ។

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១.** -

ដីកានេះមានគោលបំណងកំណត់ និងដាក់ឱ្យអនុវត្តកម្រៃសេវាប្រមូល សម្អាត និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ មានលក្ខណៈសមស្របតាមស្ថានភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានប្រកបដោយប្រសិទ្ធភាពនិងតម្លាភាពស្រប តាមគោលការណ៍នៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបានកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន ។

**ប្រការ២.** –

ដីកានេះត្រូវបានដាក់ ឱ្យអនុវត្តសេវាគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជនក្នុងក្រុងសិរីសោភ័ណ នៃខេត្តបន្ទាយមានជ័យ ដោយបានកែសម្រួលតម្លៃសេវាតាមប្រភេទ និងទីតាំងកម្រៃសេវាផ្សេងៗទៀតដូចដែលបានកំណត់ក្នុងប្រកាសអន្តរក្រសួងលេខ:១៩៥ប្រក.បស្ណ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងបរិស្ថាន ។

**ប្រការ៣.** –

ដីកានេះគឺមានសុពលភាពក្រោយពេលដែលក្រុមប្រឹក្សាក្រុងប្រជុំអនុមត័រួច និងអស់សុពលភាពក្រោយពេលក្រុមប្រឹក្សាធ្វើវិសោធនកម្ម ឬលុបចោលដីកានេះទាំងស្រុង ។

**ប្រការ៤.** –

ដីកានេះ មានវិសាលភាពក្នុងការអនុវត្តការយកតម្លៃសេវា សម្អាតប្រមូល ដឹកជញ្ជូនសំរាម និងសេវា គ្រប់គ្រងទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនក្រុងសិរីសោភ័ណ នៃខេត្តបន្ទាយមានជ័យ ។

ដីកានេះ ពុំមានវិសាលភាពការអនុវត្តការយកកម្រៃសេវាសម្អាតប្រមូល គ្រប់គ្រង សំណល់ឧស្សាហកម្មនិងសំណល់គ្រោះថ្នាក់ឡើយលើកលែងតែក្នុងករណីមានការផ្ទេរ ឬប្រគល់មុខងារបន្ថែម ។



អាសយដ្ឋាន: ផ្លូវជាតិលេខ៥៦A ភូមិខ្លាកូនចាស់ សង្កាត់កំពង់ស្វាយក្រុងសិរីសោភ័ណ
Page: www.facebook.com/រដ្ឋបាលក្រុងសិរីសោភ័ណ - serieysophon municipality
Telegram: 092 293 939/ 017 538 802/012 311 811

**ប្រការ៥. –**

ប្រជាពលរដ្ឋ ជាម្ចាស់សំរាម សំណល់រឹង គ្រប់លំនៅឋាន គ្រប់អាជីវកម្ម ត្រូវមានកាតព្វកិច្ចវេចខ្ចប់ គ្រប់គ្រងទុកដាក់សំរាម សំណល់រឹង របស់ខ្លួន នៅតាមទីតាំងសមស្រប នៃលំនៅឋាន សាមីអាជីវកម្មប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

## ជំពូកទី២
## កម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្រុងសិរីសោភ័ណ

**ប្រការ៦. –**

កម្រៃសេវាការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនជាក់ស្ដែងក្នុងក្រុងសិរីសោភ័ណ គឺជាកម្រៃសេវាដែលរាប់បញ្ចូលការប្រមូល ការបោសសម្អាត ដឹកជញ្ជូន និងកម្រៃសេវាទីលានទុកដាក់សំរាម ។ តម្រៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនជាក់ស្ដែងក្នុងក្រុងសិរីសោភ័ណត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃដីកានេះ ។

**ប្រការ៧. –**

ត្រូវបានកំណត់ការបង់កម្រៃសេវាការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅតាមលទ្ធភាពចំពោះគ្រួសារ ឬប្រជាពលរដ្ឋទាំងឡាយដែលមានប័ណ្ណសមធម៌ (ក្រីក្រប្រភេទ១ និងក្រីក្រប្រភេទ២) ។

## ជំពូកទី៣
## អវសានបញ្ញត្តិ

**ប្រការ៨. –**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីដីកានេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៩. –**

ដីកានេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ប្រការ១០. –**

ក្រុមប្រឹក្សាក្រុង គណៈអភិបាលក្រុងការិយាល័យ អង្គភាពចំណុះរដ្ឋបាលក្រុង ប្រតិបត្តិករពាក់ព័ន្ធផ្សេងទៀត និងប្រជាពលរដ្ឋ អ្នកប្រើប្រាស់សេវាទាំងអស់ក្នុងក្រុងសិរីសោភ័ណ ត្រូវអនុវត្តដីកានេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃ ចន្ទ ៤រោច ខែ ស្រាពណ៍ ឆ្នាំ ម្សាញ់ ព.ស.២៥៦៩
សិរីសោភ័ណ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០២៥
**ប្រធានក្រុមប្រឹក្សាក្រុង**

ជាម សុខ

**កន្លែងទទួល:**
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងបរិស្ថាន
- រដ្ឋបាលខេត្តបន្ទាយមានជ័យ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- មន្ទីរបរិស្ថានខេត្ត
  ( ដើម្បីគោរពជូនជ្រាប )
- ដូចប្រការ ១០- ឯកសារ - កាលប្បវត្តិ



អាសយដ្ឋាន: ផ្លូវជាតិលេខ៥៦A ភូមិខ្លាកូនចាស់ សង្កាត់កំពង់ស្វាយក្រុងសិរីសោភ័ណ
*Page; www.facebook.com/*រដ្ឋបាលក្រុងសិរីសោភ័ណ - ***serieysophon municipality***
Telegram: 092 291 929/ 017 538 802/012 311 811

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តបន្ទាយមានជ័យ

រដ្ឋបាលក្រុងសិរីសោភ័ណ

## ឧបសម្ព័ន្ធ

ភ្ជាប់នឹងដីកាលេខ.១៧....ដក/សរគ. ចុះថ្ងៃទី ..០១...... ខែ.កក្កដា.. ឆ្នាំ២០២៥

ស្តីពីការកំណត់ និងដាក់ឱ្យអនុវត្តតម្លៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្រុងសិរីសោភ័ណ

| ល.រ | ប្រភេទទីតាំងបង្កើតសំរាម សំណល់រឹងទីប្រជុំជន | ឯកតា | កម្រៃអតិបរមានៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនក្រុង | | | តម្លៃឯកភាព |
|---|---|---|---|---|---|---|
| | | | សេវាសម្អាតប្រមូលដឹក | សេវាទីលាន | សេវាគ្រប់គ្រង (សរុប) | |
| ១ | ២ | ៣ | ៤ | ៥ | ៦=៤+៥ | 7 |
| ក | លំនៅឋាន | | | | | |
| I | លំនៅឋានរស់នៅធម្មតា | | | | | |
| | ១.ផ្ទះល្វែងជាន់ផ្ទាល់ដី | រ/ខែ | 9,200 | 2,000 | 11,200 | 10,000 |
| | ២.ផ្ទះល្វែងជាន់ទី១ឡើងទៅ | រ/ខែ | 6,000 | 2,000 | 8,000 | 4,000 |
| | ៣.ផ្ទះដីឡូត៍ធម្មតា | រ/ខែ | 12,000 | 2,400 | 14,400 | 12,000 |
| | ៤.ភូមិគ្រឹះដីតូចជាង ៣០០ម២ | រ/ខែ | 27,600 | 4,800 | 32,400 | 22,000 |
| | ៥.ភូមិគ្រឹះផ្ទៃដីចាប់ពី ៣០០-៦០០ម២ | រ/ខែ | 50,000 | 7,200 | 57,200 | 30,000 |
| | ៥.ភូមិគ្រឹះផ្ទៃដីធំជាង ៦០០ម២ | រ/ខែ | សមាមាត្រ | | | |
| II | លំនៅឋានក្នុងបុរី/ក្រុងរណប | | | | | |
| | ១.ផ្ទះល្វែង | រ/ខែ | 11,200 | 2,000 | 13,200 | 12,000 |
| | ២.វីឡាភ្លោះ | រ/ខែ | 26,800 | 4,000 | 30,800 | 22,800 |
| | ៣.វីឡាទោលផ្ទៃដីតូចជាង៣០០ម២ | រ/ខែ | 36,800 | 4,800 | 41,600 | 30,000 |
| III | ខុនដូ/អាផាតមិន (គិតចំនួនយូនីត) | | | | | |
| | ១.តូចជាង៣បន្ទប់/យូនីត | រ/យូនីត.ខែ | 18,400 | 2,400 | 20,800 | 15,000 |
| | ២.ចាប់ពី៣បន្ទប់/យូនីត | រ/យូនីត.ខែ | សមាមាត្រ | | | |
| IV | ផ្ទះជួលឱ្យកម្មករ ( គិតចំនួនបន្ទប់ ) | | | | | |
| | ១.ផ្ទះ/អគារជួលអោយកម្មករស្នាក់នៅ | រ/បន្ទប់.ខែ | 4,800 | 1,600 | 6,400 | 5,600 |
| V | ផ្ទះជួលឱ្យបរទេសស្នាក់នៅ | | | | | |
| | ១.ផ្ទះជួលឱ្យបរទេសស្នាក់នៅ | រ/ខែ | 9,600 | 3,200 | 12,800 | 12,800 |

| | | | | | | |
|---|---|---|---|---|---|---|
| ខ | ទីតាំងអាជីវកម្មទូទៅ | | | | | |
| I | ផ្ទះធ្វើអាជីវកម្មទូទៅ | | | | | |
| | ១.ទំហំផ្ទះ១ល្វែង | រ/ខែ | 44,400 | 6,000 | 50,400 | 20,000 |
| | ២.ទំហំផ្ទះ២ល្វែងឡើង | រ/ខែ | 88,800 | 12,000 | 100,800 | 40,000 |
| II | ឱសថស្ថាន | | | | | |
| | ១.ទំហំផ្ទះ១ល្វែង | រ/ខែ | 44,400 | 6,000 | 50,400 | 25,000 |
| | ២.ទំហំផ្ទះ២ល្វែងឡើង | រ/ខែ | សមាមាត្រ | | | |
| III | ភោជនីយដ្ឋាន/អាហារដ្ឋាន | | | | | |
| | ១.អាហារដ្ឋានផ្ទះ១ល្វែង ( ១ជាន់ ) | រ/ខែ | 60,800 | 8,000 | 68,800 | 40,000 |
| | ២.ភោជនីយដ្ឋានផ្ទះ១ល្វែង ( ១ជាន់ ) | រ/ខែ | 101,200 | 13,200 | 114,400 | 100,600 |
| | ៣.ភោជនីយដ្ឋាន/អាហារដ្ឋានធំជាង១ល្វែង | រ/ខែ | សមាមាត្រ | | | |
| | ៤.ភោជនីយដ្ឋានប៊ូហ្វេ ( គិតផ្ទៃអាគារ ) | រ/ម២.ខែ | 2,000 | 400 | 2,400 | 1,680 |
| គ | សណ្ឋាគារនិងផ្ទះសំណាក់ | | | | | |
| I | ប៊ឹងហ្គាឡូ ( គិតចំនួនបន្ទប់ ) | | | | | |
| | ១.ប៊ឹងហ្គាឡូ | រ/បន្ទប់.ខែ | 29,600 | 4,000 | 33,600 | 33,600 |
| II | សណ្ឋាគារ ( គិតចំនួនបន្ទប់ ) | | | | | |
| | ១.មានអាហារដ្ឋាន | រ/បន្ទប់.ខែ | 22,400 | 3,200 | 25,600 | 12,800 |
| | ២.គ្មានអាហារដ្ឋាន | រ/បន្ទប់.ខែ | 11,200 | 1,600 | 12,800 | 8,600 |
| III | ផ្ទះសំណាក់ ( គិតជាបន្ទប់ ) | | | | | |
| | ១.ផ្ទះសំណាក់ | រ/បន្ទប់.ខែ | 8,400 | 1,200 | 9,600 | 8,600 |
| ឃ | មណ្ឌលកម្សាន្ត | | | | | |
| I | រង្គសាល-ក្លឹប ( គិតជាផ្ទៃអគារ ) | | | | | |
| | ១.ទំហំតូចជាង២០០ម២ | រ/ខែ | 551,600 | 36,000 | 587,600 | 400,000 |
| | ២.ទំហំចាប់ពី២០០-៤០០ម២ | រ/ខែ | 1,103,200 | 72,000 | 1,175,200 | 1,155,200 |
| | ៣.ទំហំធំជាង៤០០ម២ | រ/ម២.ខែ | 3,200 | 400 | 3,600 | 1,500 |
| II | KTV ( គិតចំនួនបន្ទប់ ) | | | | | |
| | ១.KTV | រ/បន្ទប់.ខែ | 51,600 | 3,600 | 55,200 | 40,000 |
| III | បៀរហ្គាឌិន/សាច់អាំង | | | | | |
| | ១.ចំណុះតិចជាង១៥គុ | រ/ខែ | 227,600 | 15,200 | 242,800 | 120,000 |
| | ២.ចំណុះចាប់ពី ១៥-៣០គុ | រ/ខែ | 455,200 | 30,000 | 485,200 | 240,000 |
| | ២.ចំណុះធំជាង៣០គុ | រ/ខែ | សមាមាត្រ | | | |
| IV | មហោស្រប/រោងភាពយន្ត | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ១.ចំណុះតិចជាង២០០នាក់ | រ/ខែ | 368,000 | 48,000 | 416,000 | 100,000 |
| | ២.ចំណុះចាប់ពី២០០-៤០០នាក់ | រ/ខែ | 735,600 | 96,000 | 831,600 | 415,000 |
| | ៣.ចំណុះធំជាង៤០០នាក់ ( គិតចំនួនកៅអី ) | រ/កៅអី.ខែ | 2,800 | 400 | 3,200 | 2,000 |
| V | **កាស៊ីណូ ( មិនគិតបញ្ចូលភោជនីយដ្ឋាន ក្លិបកម្សាន្តផ្សេងៗ )** | | | | | |
| | ១.ចំណុះតិចជាង២០០នាក់ | រ/ខែ | 2,941,600 | 192,000 | 3,133,600 | 3,133,600 |
| | ២.ចំណុះចាប់ពី២០០-៤០០នាក់ | រ/ខែ | 5,883,200 | 384,000 | 6,267,200 | 6,267,200 |
| | ៣.ចំណុះលើសពី៤០០នាក់ឡើង | រ/ខែ | សមាមាត្រ | | | |
| ង | **មជ្ឈមណ្ឌលពាណិជ្ជកម្ម/លក់ដូរ** | | | | | |
| I | **ផ្សារទំនើប ( គិតផ្ទៃអគារ )** | | | | | |
| | ១.អគារលក់ទំនិញ/ផ្សារទំនើប | រ/ម$^២$.ខែ | 2,400 | 400 | 2,800 | 1,500 |
| II | **ផ្សារលក់ដូរធម្មតា ( គិតផ្ទៃទីតាំងលក់ដូរ )** | | | | | |
| | ១.ផ្សារ | រ/ម$^២$.ខែ | 2,000 | 400 | 2,400 | 2,400 |
| III | **ហាងទំនិញ (គិតផ្ទៃអគារ)** | | | | | |
| | ១.ហាងទំនិញ | រ/ម$^២$.ខែ | 1,200 | 400 | 1,600 | 700 |
| | ២.មីនីម៉ាត | រ/ម$^២$.ខែ | 1,200 | 400 | 1,600 | 800 |
| IV | **អគារពាណិជ្ជកម្ម (គិតផ្ទៃអគារ)** | | | | | |
| | ១.អគារពាណិជ្ជកម្ម | រ/ម$^២$.ខែ | 1,600 | 400 | 2,000 | 1,200 |
| ច | **មន្ទីរពេទ្យ/សុខភាពឯកជន-ស្វយ័ត** | | | | | |
| I | **មន្ទីរពេទ្យ (គិតចំនួនគ្រែ)** | | | | | |
| | ១.មន្ទីរពេទ្យ | រ/គ្រែ.ខែ | 16,800 | 2,400 | 19,200 | 9,000 |
| II | **មន្ទីរសម្ភព(គិតចំនួនគ្រែ)** | | | | | |
| | ១.មន្ទីរសម្ភព | រ/គ្រែ.ខែ | 16,800 | 2,400 | 19,200 | 9,000 |
| III | **មន្ទីរសម្រាកព្យាបាលជំងឺ(គិតចំនួនគ្រែ)** | | | | | |
| | ១.មន្ទីរសម្រាកព្យាបាលជំងឺ | រ/គ្រែ.ខែ | 11,200 | 1,600 | 12,800 | 9,000 |
| IV | **បន្ទប់ពិគ្រោះជំងឺ** | | | | | |
| | ១.បន្ទប់ពិគ្រោះជំងឺ | រ/ខែ | 29,600 | 4,000 | 33,600 | 25,800 |
| ឆ | **គ្រឹះស្ថានអប់រំឯកជន-ស្វយ័ត/អង្គការ** | | | | | |
| I | **សាកល/មហាវិទ្យាល័យ** | | | | | |
| | ១.តិចជាង១០បន្ទប់ | រ/ខែ | 248,400 | 54,000 | 302,400 | 300,000 |
| | ២.ចាប់ពី១០-៣០បន្ទប់ | រ/ខែ | 744,800 | 162,000 | 906,800 | 600,000 |
| | ៣.ច្រើនជាង ៣០បន្ទប់ | រ/ខែ | សមាមាត្រ | | | |
| II | **សាលារៀនចំណេះទូទៅ** | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ១.តិចជាង១០បន្ទប់ | ៛/ខែ | 165,600 | 36,000 | 201,600 | 100,000 |
| | ២.ចាប់ពី១០-៣០បន្ទប់ | ៛/ខែ | 496,400 | 108,000 | 604,400 | 250,000 |
| | ៣.ច្រើនជាង ៣០បន្ទប់ | ៛/ខែ | | សមាមាត្រ | | |
| III | **សាលាអង្គការមិនយកថ្លៃសិក្សា** | | | | | |
| | ១.តិចជាង១០បន្ទប់ | ៛/ខែ | 124,400 | 27,200 | 151,600 | 100,000 |
| | ២.ចាប់ពី១០បន្ទប់ឡើង | ៛/ខែ | | សមាមាត្រ | | |
| IV | **សាលារៀនកម្រិតអន្តរជាតិ** | | | | | |
| | ១.តិចជាង១០បន្ទប់ | ៛/ខែ | 620,800 | 54,000 | 674,800 | 330,000 |
| | ២.ចាប់ពី ១០-២០បន្ទប់ | ៛/ខែ | 1,241,200 | 108,000 | 1,349,200 | 670,000 |
| | ៣.ច្រើនជាង ២០បន្ទប់ | ៛/ខែ | | សមាមាត្រ | | |
| ជ | **គ្រឹះស្ថានអប់រំថ្មី** | | | | | |
| I | **សាលាចំណេះទូទៅ** | | | | | |
| | ១.សាលាចំណេះទូទៅ | ៛/ខែ | 276,000 | 72,000 | 348,000 | 250,000 |
| ឈ | **ក្រុមហ៊ុនឯកជន** | | | | | |
| I | **ក្រុមហ៊ុនឯកជនទូទៅ** | | | | | |
| | ១.បុគ្គលិកតិចជាង១៥នាក់ | ៛/ខែ | 131,200 | 8,800 | 140,000 | 60,600 |
| | ២.បុគ្គលិកចាប់ពី១៥-៥០ | ៛/ខែ | 436,800 | 28,800 | 465,600 | 200,000 |
| | ៣.បុគ្គលិកលើសពី៥០នាក់ | ៛/ខែ | | សមាមាត្រ | | |
| II | **ធនាគារ/គ្រឹះស្ថានហិរញ្ញវត្ថុ/មីក្រូហិរញ្ញវត្ថុ** | | | | | |
| | ១.បុគ្គលិកតិចជាង២៥នាក់ | ៛/ខែ | 356,400 | 23,600 | 380,000 | 200,000 |
| | ២.បុគ្គលិកចាប់ពី២៥-៥០នាក់ | ៛/ខែ | 712,400 | 46,800 | 759,200 | 300,000 |
| | ៣.បុគ្គលិកលើសពី៥០នាក់ | ៛/ខែ | | សមាមាត្រ | | |
| ៣ | **ស្ថានីយ-ដេប៉ូប្រេងឥន្ធនៈ** | | | | | |
| I | មានកន្លែងលាងរថយន្ត ឬហាងទំនិញ | ៛/ខែ | 303,600 | 20,000 | 323,600 | 300,000 |
| II | គ្មានកន្លែងលាងរថយន្ត ឬហាងទំនិញ | ៛/ខែ | 125,200 | 8,400 | 133,600 | 120,000 |
| ផ | **ទីតាំងស្តុក/ផ្ទេរទំនិញ** | | | | | |
| I | **កំពង់ផែ (គិតផ្ទៃដី)** | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| | ១.កំពង់ផែ | ៛/ម$^{២}$.ខែ | 2,800 | 400 | 3,200 | 3,200 |
| II | **ស្ថានីយរថភ្លើង (គិតផ្ទៃអគារ)** | | | | | |
| | ១.ស្ថានីយរថភ្លើង | ៛/ម$^{២}$.ខែ | 2,800 | 400 | 3,200 | 3,200 |
| III | **ចំណតរថយន្តអ្នកធ្វើដំណើរ (គិតផ្ទៃអគារ)** | | | | | |
| | ១.ចំណតរថយន្តអ្នកដំណើរ | ៛/ម$^{២}$.ខែ | 2,800 | 400 | 3,200 | 2,880 |
| IV | **ព្រលានយន្តហោះ (គិតផ្ទៃអគារ)** | | | | | |
| | ១.ព្រលានយន្តហោះ | | 4,000 | 400 | 4,400 | 4,400 |
| V | **ផែស្ងួត (គិតផ្ទៃដី)** | | | | | |
| | ១.ទំហំតូចជាង ១០០០០ម២ | ៛/ខែ | 735,600 | 48,000 | 783,600 | 390,000 |
| | ២.ទំហំចាប់ពី ១០០០០-២០០០០ម២ | ៛/ខែ | 1,470,800 | 96,000 | 1,566,800 | 740,000 |
| | ៣.ទំហំធំជាង ២០០០០ម២ | ៛/ម$^{២}$.ខែ | 800 | 400 | 1,200 | 1,200 |
| VI | **ឃ្លាំងស្តុកទំនិញ (គិតផ្ទៃឃ្លាំង)** | | | | | |
| | ១.ទំហំតូចជាង ៣០០ម២ | ៛/ខែ | 110,400 | 7,200 | 117,600 | 115,600 |
| | ២.ទំហំចាប់ពី ៣០០ដល់៦០០ម២ | ៛/ខែ | 220,800 | 14,400 | 235,200 | 231,200 |
| | ៣.ទំហំធំជាង ៦០០ម២ | ៛/ម$^{២}$.ខែ | 400 | 400 | 800 | 400 |
| VII | **ឃ្លាំងស្តុកប្រេងឥន្ធនៈ** | | | | | |
| | ១.ពោងស្តុកតិចជាង៣ | ៛/ខែ | 662,000 | 43,200 | 705,200 | 350,000 |
| | ២.ពោងស្តុកចាប់ពី ៣-៤ | ៛/ខែ | 1,324,000 | 86,400 | 1,410,400 | 350,000 |
| | ៣.ពោងស្តុកលើសពី ៤ | ៛/ខែ | សមាមាត្រ | | | |
| VIII | **ចំណតរថយន្តដឹក/ផ្ទេរទំនិញ (គិតផ្ទៃដី)** | | | | | |
| | ១.ទំហំតូចជាង៥០០ម២ | ៛/ខែ | 147,200 | 9,600 | 156,800 | 100,000 |
| | ២. ទំហំចាប់ពី ៥០០- ១៥០០ម$^{២}$ | ៛/ខែ | 441,600 | 28,800 | 470,400 | 250,000 |
| | ៣. ទំហំធំជាង ១៥០០ ម$^{២}$ | ៛/ម$^{២}$.ខែ | 400 | 400 | 800 | 500 |
| IX | **អាគារ/ឃ្លាំងលក់រថយន្ត-ម៉ូតូ (គិតផ្ទៃអគារ)** | | | | | |
| | ១.ទំហំតូចជាង ២០០ម$^{២}$ | ៛/ខែ | 64,400 | 4,400 | 68,800 | 60,000 |
| | ២.ទំហំចាប់ពី២០០-៤០០ម$^{២}$ | ៛/ខែ | 128,800 | 8,400 | 137,200 | 100,000 |
| | ៣.ទំហំធំជាង៤០០ម$^{២}$ | ៛/ម$^{២}$.ខែ | 400 | 400 | 800 | 400 |
| ឋ | **រោងចក្រ សិប្បកម្ម** | | | | | |
| I | **រោងចក្រ/ឧស្សាហកម្ម** | | | | | |
| | ១.កម្មករ/បុគ្គលិកក្រោម២៥០នាក់ | ៛/ខែ | 919,200 | 60,000 | 979,200 | 800,000 |
| | ២.កម្មករ/បុគ្គលិកចាប់ពី ២៥០- ៥០០នាក់ | ៛/ខែ | 1,838,400 | 120,000 | 1,958,400 | 1,700,000 |
| | ៣.កម្មករ/បុគ្គលិកលើសពី ៥០០នាក់ | ៛/ខែ | សមាមាត្រ | | | |

| | | | | | | |
|---|---|---|---|---|---|---|
| II | **សិប្បកម្ម/ឧស្សាហកម្មធុនស្រាល** | | | | | |
| | ១. បុគ្គលិក/កម្មករក្រោម ៥០ នាក់ | ៛/ខែ | 184,000 | 12,000 | 196,000 | 190,000 |
| | ១. បុគ្គលិក/កម្មករចាប់ពី ៥០ នាក់ | ៛/ខែ | | សមាមាត្រ | | |
| ឌ | **ស្ថានទូត-កុងស៊ុល-អង្គការ** | | | | | |
| I | **ស្ថានទូត-កុងស៊ុល( គិតផ្ទៃដី )** | | | | | |
| | ១.តូចជាង ១២០០ម២ | ៛/ខែ | | | | |
| | ២.ចាប់ពី ១២០០ម២ | ៛/ម២.ខែ | | | | |
| II | **អង្គការមិនមែនរដ្ឋាភិបាល** | ៛/ខែ | 368,000 | 24,000 | 392,000 | 100,000 |
| ឍ | **ស្ថាប័ន/អង្គភាពរដ្ឋ** | | | | | |
| I | ក្រសួង ស្ថាប័ន | ៛/ខែ | | | | |
| II | មន្ទីរអង្គភាពរដ្ឋ | ៛/ខែ | 92,000 | 12,000 | 104,000 | 104,000 |
| ណ | **ផ្សេងៗ** | | | | | |
| I | **ការធ្វើកម្មវិធីនៅទីសាធារណៈ** | | | | | |
| | ១.កម្មវិធីអ្នកចូលរួមតិចជាង ១០០០នាក់/ថ្ងៃ | ៛/ថ្ងៃ | 368,000 | 24,000 | 392,000 | 250,000 |
| | ២.កម្មវិធីអ្នកចូលរួមចាប់ពី ១០០០-១៥០០នាក | ៛/ថ្ងៃ | 551,600 | 36,000 | 587,600 | 385,200 |
| | ៣.កម្មវិធីអ្នកចូលរួមលើសពី ១៥០០ នាក់/ថ្ងៃ | ៛/ថ្ងៃ | | | | |
| | ៤. ការប្រគុំតន្ត្រីក្នុង១ថ្ងៃ | ៛/ថ្ងៃ | 1,103,200 | 72,000 | 1,175,200 | 800,000 |
| II | **ការលក់ដូរចល័តតាមដងផ្លូវ( ក្នុង១ថ្ងៃ )** | | | | | |
| | ១.ការលក់ដូរផ្សេងៗតាមដងផ្លូវ | ៛/ថ្ងៃ | 400 | 400 | 800 | 500 |
| III | **ការដ្ឋានសាងសង់ផ្សេងៗ( គិតបរិមាណ )** | | | | | |
| | ១.បញ្ចេញសំណល់រឹងចេញពីការដ្ឋានដោយប្រើប្រាស់ក្រុមហ៊ុន ផ្តល់ សេវាប្រមូលនិងដឹកជញ្ជូន | ៛/តោន | 153,200 | 20,000 | 173,200 | 100,000 |

**សំគាល់៖** - ដោយផ្អែកលើប្រភេទ និងតម្លៃអតិបរមា នៃទីតាំងបង្កើតសំរាម សំណល់រឹងទីប្រជុំជនដូចដែលមានចែងក្នុងតារាងខាងលើ រដ្ឋបាលខេត្ត ក្រុងបានកំណត់តម្លៃសេវាលម្អិតជាក់ស្តែងនីមួយៗស្របនឹងស្ថានភាពសេដ្ឋកិច្ច និង មិនយកតម្លៃសេវាពីប្រជាជនមានប័ណ្ណ ក្រ១ ក្រ២

- តម្លៃសេវាទីលានប្រកបដោយអនាម័យ 12000( មួយរយម្ភៃពាន់ )រៀលក្នុងមួយតោន

- តារាងកំណត់ថ្លៃសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន នឹងមានការប្រែប្រួលក្នុងករណីចាំបាច់ ដើម្បីធានានិរន្តរភាពក្នុងការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពខ្ពស់ ។